archive.today
webpage capture
Saved from https://www.vodkhmer.news/2020/05/08/company-dangkor-runs-factory-sell-
no other snapshots from this url
Redirected from https://vodkhmer.news/2020/05/08/company-dangkor-runs-factory-sell-worke
no other snapshots from this url
All snapshots from host vodkhmer.news
from host www.vodkhmer.news
24 Apr 2024 02:36:34 UTC
Webpage Screenshot
share download .zip report bug or abuse



# រោងចក្រមួយនៅខណ្ឌដង្កោលក់សម្ភារឡាយឡុងយកលុយផ្ដល់សំណងជូនកម្មករ

ព័ត៌មានជាតិ | ការងារ | កូវីដ-១៩

លោក យុត សុគន្ធ | ០៨ ឧសភា ២០២០ ម៉ោង ១៦:៤១




ទិដ្ឋភាពនៅខាងមុខរោងចក្រផលិតស្បែកជើង គុន ដា ហ្វូតវែរ (KUN DA Footwear Co,. Ltd) ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ ព្រឹកថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០។ (ហ៊ុ ឆាយ)

រោងចក្រផលិតស្បែកជើង គុន ដា ហ្វូតវែរ (KUN DA Footwear Co,. Ltd) ស្ថិតក្នុងខណ្ឌដង្កោ រាជធានីភ្នំពេញ កំពុងដំណើរការលក់ឡាយឡុងសម្ភារក្នុងរោងចក្រ ដើម្បីយកលុយដោះស្រាយសំណងជូនកម្មករ។

កាលពីថ្ងៃទី២៩ ខែមេសា ថៅកែរោងចក្រ គុន ដា នៅភូមិម៉ី សង្កាត់ដង្កោ បានប្រកាសឱ្យកម្មករលក់ឡាយឡុងសម្ភារក្នុងរោងចក្រ ដើម្បីយកលុយទូទាត់ប្រាក់អតីតភាពការងារជូនកម្មករ ដោយអះអាងថា រោងចក្រមួយនេះពុំមានលទ្ធភាពបន្តដំណើរការអាជីវកម្មតទៅទៀតបានទេ។

ក្រោមការសម្របសម្រួលពីមន្ត្រីក្រសួងការងារ គឺក្រុមកម្មករបានដាក់ដេញថ្លៃលក់ឡាយឡុងសម្ភារក្នុងរោងចក្រចំនួនពីរថ្ងៃហើយ តាំងពីថ្ងៃទី៧ និងថ្ងៃទី៨ ខែឧសភានេះ ប៉ុន្តែ ការដេញថ្លៃចំនួនពីរថ្ងៃនេះ

១៨០០០ដុល្លារ ដែលកម្មករថា តម្លៃនេះថោកពេក មិនអាចទូទាត់សំណងជូនកម្មករបានសមរម្យ។

កម្មការិនីផ្នែកត្រួតពិនិត្យ អ្នកស្រី ហុង ស្រីមុំ ដែលអះអាងថា បម្រើការងារនៅរោងចក្រ គុន ដា ៧ឆ្នាំ ប្រាប់វីអូឌីនៅមុខរោងចក្រថា ការដេញថ្លៃរយៈពេលពីរថ្ងៃនេះ គឺឈ្នួញឱ្យតម្លៃសម្ភារក្នុងរោងចក្រនេះបានតែ ១៨០០០ដុល្លារប៉ុណ្ណោះ ដែលធ្វើឱ្យក្រុមកម្មករមិនអាចលក់បាន។

កម្មការិនីរូបនេះបន្តថា ចំនួនលុយត្រឹម ១៨០០០ដុល្លារនោះ បើបែងចែកឱ្យកម្មករ គឺបានតិចតួចណាស់ ដោយថា ម្នាក់ទទួលបានលុយប្រហែល ៣០ ទៅ ៤០ដុល្លារប៉ុណ្ណោះ ខណៈកម្មករមួយចំនួនធំបានបម្រើការងារនៅរោងចក្រនេះ ចន្លោះពី៧ ទៅជាង ១០ឆ្នាំ។

> អ្នកស្រីបន្ថែមថា៖ «បានត្រឹម ២ម៉ឺន ក៏ពួកយើងមិនលក់ដែរ ពីព្រោះតិចពេក ពេលបើកមក មិនដឹងបានប៉ុន្មានម្នាក់។ ពីព្រោះពួកខ្ញុំខ្លះធ្វើការងារនៅទីនេះរាប់ឆ្នាំហើយ។ បើបើកមក បានម្នាក់ ២០ ទៅ ៣០ និង ៤០ដុល្លារ មិនដឹងយកមកធ្វើអី។ អីចឹង វាមិនសមទេ»។

តំណាងកម្មករម្នាក់ដែលសុំមិនបញ្ចេញឈ្មោះក្រោមហេតុផលបារម្ភពីសុវត្ថិភាព បានប្រាប់វីអូឌីនៅក្នុងរោងចក្រថា រោងចក្រ គុន ដា មានទាំងកម្មករប្រើប្រាស់កិច្ចសន្យាមិនកំណត់ និងកម្មករប្រើប្រាស់កិច្ចសន្យាកំណត់។

តំណាងកម្មកររូបនេះបន្តថា កម្មករជាង ១៥០នាក់ដែលជាកម្មករពេញសិទ្ធិនោះ ភាគច្រើនពួកគេបម្រើការងារនៅរោងចក្រ គុន ដា ចន្លោះពី ៧ ទៅជាង ១០ឆ្នាំ។

> លោកបន្ថែមថា៖ «បើអត្ថប្រយោជន៍ដែលកម្មករទទួលបានគឺច្រើនដែរ ប៉ុន្តែ ការលក់សម្ភារក្នុងរោងចក្រហ្នឹង វាបានតិច។ អីចឹងមិនដឹងថា វាសមស្របដែលកម្មករអាចទទួលបាន ឬអត់។ បើគេបង់តាមផ្លូវច្បាប់ វាមាន ៤ទៅ ៥ចំណុចដែរ»។

កម្មការិនីផ្នែកបិទបាតស្បែកជើងម្នាក់ទៀត អ្នកស្រី ខុន គុននេញ និយាយថា ចាប់តាំងពីថៅកែប្រកាសឱ្យកម្មករលក់សម្ភារឡាយឡុង គឺក្រុមកម្មករដេកយាមមុខរោងចក្រជាង ១០ថ្ងៃហើយ ដើម្បីការពារខ្លាចមានការដឹកសម្ភារចេញពីរោងចក្រ។

កម្មការិនីរូបនេះ ស្នើក្រសួងការងារ និងសមត្ថកិច្ចស្វែងរកថៅកែឱ្យចេញមុខទទួលខុសត្រូវក្នុងការដោះស្រាយសំណងតាមផ្លូវច្បាប់ជូនកម្មករ ដោយថាកម្មករកំពុងប្រឈមអត់ការងារ និងខ្វះខាតក្នុងជីវភាពក្នុងគ្រួសារ។

> អ្នកស្រីបន្ថែមថា៖ «ខ្ញុំមានតែសំណូមពរឱ្យអាជ្ញាធរមកជួយដោះស្រាយឱ្យបានឆាប់ៗ។ ឆាប់បានលុយ ឆាបបានទៅរកការងារកន្លែងថ្មីធ្វើ។ ឥលូវយើងពិបាកដែរ យើងអត់លុយ។ យើងត្រូវបង់ធនាគារ ការចាយវាយប្រចាំថ្ងៃ លុយកូនរៀន បង់ទឹកភ្លើងនិយាយទៅផលលំបាកច្រើន»។

មន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដែលចុះសម្របសម្រួលដេញថ្លៃសម្ភារនៅរោងចក្រ គុន ដា ព្រឹកមិញនេះ សុំមិនផ្ដល់បទសម្ភាសន៍ជាមួយវីអូឌីទេ ដោយថា រឿងនេះកំពុងស្ថិតក្នុងដំណើរការដេញថ្លៃនៅឡើយ។

មន្ត្រីផ្នែកច្បាប់ និងដោះស្រាយវិវាទនៃសម្ព័ន្ធសហជីពស៊ីខៅឌូ លោក ស៊ាង យ៉ូត មានប្រសាសន៍ថា តាមផ្លូវច្បាប់ នៅពេលរោងចក្របិទ ឬបញ្ឈប់កម្មករពីការងារ គឺការដោះស្រាយសំណងជូនកម្មករពឹងផ្អែកទៅលើកិច្ចសន្យាការងារ។

មន្ត្រីផ្នែកច្បាប់ និងដោះស្រាយវិវាទរូបនេះបន្តថា ក្នុងករណីកម្មករប្រើប្រាស់កិច្ចសន្យាមិនកំណត់ ថៅកែត្រូវទូទាត់សំណងជូនកម្មករចំនួន ៥ចំណុចមានប្រាក់ខែចុងក្រោយ ប្រាក់ជូនដំណឹង ប្រាក់អតីតភាពការងារ ប្រាក់ជំងឺចិត្ត និងប្រាក់ដំណាច់ឆ្នាំ។

ចំពោះកម្មករដែលប្រើប្រាស់កិច្ចសន្យាកំណត់វិញ លោកថា ថៅកែត្រូវទូទាត់សំណងជូនពួកគេចំនួន ៤ចំណុចមាន ប្រាក់ឈ្នួលចុងក្រោយ ប្រាក់៥ភាគរយ ប្រាក់ដំណាច់ឆ្នាំដែលនៅសល់ និងប្រាក់ជំងឺចិត្ត ក្នុងករណីកិច្ចសន្យាការងាររបស់ពួកគេនៅសល់។

លោក ស៊ាង យ៉ូត បន្ថែមទៀតថា ក្នុងករណីថៅកែរត់បាត់ គ្មានលុយទូទាត់សំណងជូនកម្មករ គឺរដ្ឋាភិបាលត្រូវស្រាវជ្រាវស្វែងរកថៅកែឱ្យមកទទួលខុសត្រូវ ឬដកលុយដែលថៅកែតម្កល់នៅក្រសួងពាណិជ្ជកម្ម ឬបញ្ចេញកញ្ចប់ថវិកាណាមួយយកមកដោះស្រាយសំណងជូនកម្មករ។

> លោកបន្ថែមថា៖ «ពេលដែលថៅកែរត់ចោល ឬក៏យើងរកថៅកែហ្នឹងមិនឃើញ។ អីចឹងអាហ្នឹងវាជាបន្ទុករបស់រដ្ឋាភិបាលក្នុងការបញ្ចេញថវិកា ឬលក់សម្ភារឡាយឡុង ឬផែកក្នុងការងារចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម ព្រោះថា ក្រុមហ៊ុនមួយអាចបើករកស៊ីបាន គឺថៅកែត្រូវយកប្រាក់មួយចំនួនមកតម្កល់នៅក្រសួងពាណិជ្ជកម្ម ដើម្បីអាចដំណើរការបាន ប៉ុន្តែ គ្រាន់តែយើងមិនដឹងថាប្រាក់តម្កល់របស់គាត់ហ្នឹងយ៉ាងម៉េចទេ»។

បើតាមកម្មការិនី អ្នកស្រី ហុង ស្រីមុំ រោងចក្រ គុន ដា មានថៅកែជាជនជាតិចិន និងមានកម្មករជាង ៣៧០នាក់បម្រើការងារ។

កាលពីថ្ងៃទី១ ខែឧសភា ប្រធានសម្ព័ន្ធសហជីពស៊ីខៅឌូ លោក គង់ អាទិត្យ មានប្រសាសន៍ថា តាមរបាយការណ៍ដែលស៊ីខៅឌូទទួលបាន គឺមានរោងចក្រចំនួន ៣ បានបិទទ្វារ ក្រោមហេតុផលគ្មានអ្នកបញ្ជាទិញ ហើយថា រោងចក្រទាំងនោះបានបិទទាំងខុសនីតិវិធីច្បាប់ និងមិនបានដោះស្រាយសំណងជូនកម្មករត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ៕

**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង

### សូមផ្តល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចូលមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

ចុចបញ្ជូន

**ព័ត៌មានថ្មីៗ** | **បោះឆ្នោត**




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រីរឿងផ្តល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល

១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤



ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហេនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ

១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣




អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការ



ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ មាណ្ណារ៉ា ជាទីប្រឹក្សាលោក



គំរាមកំហែង

១១ កុម្ភៈ ២០២៣ ម៉ោង ១៥:៤៦



ហ៊ុន សែន

១១ កុម្ភៈ ២០២៣ ម៉ោង ១៤:៥៣






VOD

VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្ដល់ព័ត៌មាន ផលិតកម្មវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។


info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ



GET IT ON Google Play

Download on the App Store






ស្វែងរកព័ត៌មាន
អំពីយើង
បណ្ណសាររូបភាព
ព័ត៌មានជាសំឡេង
ក្រុមសីលធម៌
ទូរទស្សន៍
VOD ENGLISH
ទំនាក់ទំនង
ទិន្នន័យចាស់ៗ
ឱកាសការងារ



© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម